ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# ក្រសួងសុខាភិបាល

# នីតិវិធីប្រតិបត្តិស្តង់ដារ (SOPs) ដើម្បីគ្រប់គ្រងអ្នកដំណើរ មកដល់អាកាសយានដ្ឋានអន្តរជាតិនៅកម្ពុជា អនុលោមតាមការរស់នៅតាមគន្លងប្រក្រតីភាពថ្មី ក្នុងបរិបទនៃជំងឺកូវីដ-១៩

ថ្ងៃទី៥ ខែធ្នូ ឆ្នាំ២០២១

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

ក្រសួងសុខាភិបាល

លេខ...៥២៣...សណ.ខល

# សេចក្តីសម្រេច

# ស្តីពី

# នីតិវិធីប្រតិបត្តិស្តង់ដារ (SOPs) ដើម្បីគ្រប់គ្រងអ្នកដំណើរមកដល់អាកាសយានដ្ឋានអន្តរជាតិនៅកម្ពុជា អនុលោមតាមការរស់នៅតាមគន្លងប្រក្រតីភាពថ្មីក្នុងបរិបទនៃជំងឺកូវីដ-១៩

# រដ្ឋមន្ត្រីក្រសួងសុខាភិបាល និងជាប្រធានគណៈកម្មការអន្តរក្រសួងដើម្បីប្រយុទ្ធនឹងជំងឺកូវីដ-១៩

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៦ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសុខាភិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣២១/០០៤ ចុះថ្ងៃទី១១ ខែមីនា ឆ្នាំ២០២១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិធានការទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ និងជំងឺឆ្លងកាចសាហាវនិងប្រកបដោយគ្រោះថ្នាក់ធ្ងន់ធ្ងរផ្សេងទៀត
- បានឃើញអនុក្រឹត្យលេខ៦៧ អនក្រ.បក ចុះថ្ងៃទី២២ ខែតុលា ឆ្នាំ១៩៩៧ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងសុខាភិបាល
- បានឃើញអនុក្រឹត្យលេខ៣៧ អនក្រ.បក ចុះថ្ងៃទី១២ ខែមីនា ឆ្នាំ២០២១ ស្តីពីវិធានការសុខាភិបាលដើម្បីទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ និងជំងឺឆ្លងកាចសាហាវនិងប្រកបដោយគ្រោះថ្នាក់ធ្ងន់ធ្ងរផ្សេងទៀត
- បានឃើញអនុក្រឹត្យលេខ៥៧ អនក្រ.បក ចុះថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២១ ស្តីពីវិធានការរដ្ឋបាលដើម្បីទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ និងជំងឺឆ្លងកាចសាហាវនិងប្រកបដោយគ្រោះថ្នាក់ធ្ងន់ធ្ងរផ្សេងទៀត
- បានឃើញអនុក្រឹត្យលេខ៨៥ អនក្រ.បក ចុះថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០២១ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈកម្មការជាតិប្រយុទ្ធនឹងជំងឺកូវីដ-១៩ /

- យោងតាមតម្រូវការចាំបាច់របស់គណៈកម្មការអន្តរក្រសួងដើម្បីប្រយុទ្ធនឹងជំងឺកូវីដ-១៩

## សម្រេច

**ប្រការ១ .-**

ត្រូវបានដាក់ឱ្យប្រើនីតិវិធីប្រតិបត្តិស្តង់ដារ (SOPs) ដើម្បីគ្រប់គ្រងអ្នកដំណើរមកដល់អាកាសយានដ្ឋានអន្តរជាតិនៅកម្ពុជា អនុលោមតាមការរស់នៅតាមគន្លងប្រក្រតីភាពថ្មីក្នុងបរិបទនៃជំងឺកូវីដ-១៩ ដែលជាឧបសម្ព័ន្ធនៃសេចក្តីសម្រេចនេះ។

**ប្រការ២ .-**

ការដាក់ឱ្យប្រើនីតិវិធីប្រតិបត្តិស្តង់ដារ (SOPs) ដើម្បីគ្រប់គ្រងអ្នកដំណើរមកដល់អាកាសយានដ្ឋានអន្តរជាតិនៅកម្ពុជា អនុលោមតាមការរស់នៅតាមគន្លងប្រក្រតីភាពថ្មីក្នុងបរិបទនៃជំងឺកូវីដ-១៩ មានវិសាលភាពអនុវត្តនៅគ្រប់អាកាសយានដ្ឋានអន្តរជាតិ។

**ប្រការ៣ .-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងសេចក្តីសម្រេចនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ៤ .-**

នាយកខុទ្ទកាល័យក្រសួងសុខាភិបាល អគ្គនាយករដ្ឋបាលនិងហិរញ្ញវត្ថុ អគ្គនាយកបច្ចេកទេសសុខាភិបាល អគ្គាធិការក្រសួងសុខាភិបាល អនុគណៈកម្មការនានាចំណុះឱ្យគណៈកម្មការអន្តរក្រសួងដើម្បីប្រយុទ្ធនឹងជំងឺកូវីដ-១៩ លេខាធិការដ្ឋានរបស់គណៈប្រតិបត្តិនៃគណៈកម្មការអន្តរក្រសួងដើម្បីប្រយុទ្ធនឹងជំងឺកូវីដ-១៩ ប្រធានគណៈកម្មការប្រយុទ្ធនឹងជំងឺកូវីដ-១៩ រាជធានី-ខេត្ត និងអង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួងសុខាភិបាល ត្រូវអនុវត្តតាមសេចក្តីសម្រេចនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃអាទិត្យ ១កើត ខែមិគសិរ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី០៥ ខែធ្នូ ឆ្នាំ២០២១

**ម៉ម ប៊ុនហេង**

**កន្លែងទទួល** :
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- គណៈប្រចាំការនៃ **គ.ប.ក.**
- ដូចប្រការ៤
- ឯកសារ-កាលប្បវត្តិ

ដើម្បីជានាឱ្យមានសង្គតិភាពក្នុងការគ្រប់គ្រងអ្នកដំណើរដែលមកដល់អាកាសយានដ្ឋានអន្តរជាតិនៅក្នុងព្រះរាជាណាចក្រកម្ពុជា និងយោងតាមសេចក្តីសម្រេចលេខ៥០៤សខល ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០២១ ស្តីពីការកែសម្រួលលក្ខខណ្ឌធ្វើដំណើរ ការអនុវត្តវិធានការសុខាភិបាល និងការធ្វើចត្តាឡីស័កនៅកម្ពុជាសម្រាប់អ្នកដំណើរចូលមកកម្ពុជា ស្របតាមគន្លងប្រក្រតីភាពថ្មី ក្រុមការងារបច្ចេកទេសនៃក្រសួងសុខាភិបាល សហការជាមួយក្រុមការងារអនុគណៈកម្មការគ្រប់គ្រងច្រកទ្វារចេញ-ចូលប្រទេស និងការធ្វើចត្តាឡីស័ក និងអនុគណៈកម្មការបច្ចេកទេសនិងព្យាបាល ព្រមទាំងអនុគណៈកម្មការពាក់ព័ន្ធ បានរៀបចំជានីតិវិធីប្រតិបត្តិស្តង់ដានេះឡើងដើម្បីដាក់ឱ្យអនុវត្ត។

## ១. មុនពេលអ្នកដំណើរមកដល់កម្ពុជា

### ១.១. មន្ត្រីអាកាសចរណ៍ស៊ីវិល

មន្ត្រីអាកាសចរណ៍ស៊ីវិល ត្រូវប្រមូលនិងផ្តល់ព័ត៌មានជើងហោះហើរ និងទិន្នន័យអ្នកដំណើរ (Flight Manifest) ដល់ផ្នែកពាក់ព័ន្ធ ដើម្បីក្រុមការងារអាចត្រៀម៖

- ចាត់ចែងក្រុមគ្រូពេទ្យយកសំណាកដើម្បីធ្វើតេស្តហ័សរកអង់ទីហ្សែនកូវីដ-១៩
- រថយន្តសម្រាប់ដឹកអ្នកដំណើរដែលគ្មានបណ្ណ ឬវិញ្ញាបនបត្រចាក់វ៉ាក់សាំងកូវីដ-១៩ ដែលបញ្ជាក់ពីការចាក់វ៉ាក់សាំងកូវីដ-១៩ ពេញលេញ ទៅកាន់កន្លែងធ្វើចត្តាឡីស័កដែលបានកំណត់ដោយក្រសួងសុខាភិបាល ឬអាជ្ញាធរមានសមត្ថកិច្ច
- រថយន្តគិលានសង្គ្រោះសម្រាប់ដឹកអ្នកដំណើរដែលទទួលបានលទ្ធផលតេស្តរហ័សរកអង់ទីហ្សែនកូវីដ-១៩ វិជ្ជមាន។

### ១.២. អ្នកដំណើរ

អ្នកដំណើរ ត្រូវត្រៀមរួចជាស្រេចនូវឯកសារ ដើម្បីបង្ហាញដល់អាជ្ញាធរពាក់ព័ន្ធ ដូចខាងក្រោម៖

#### ១.២.១. សម្រាប់អ្នកដំណើរជាជនជាតិខ្មែរ និងជនបរទេស

- លិខិតឆ្លងដែន
- បណ្ណ ឬវិញ្ញាបនបត្រចាក់វ៉ាក់សាំងកូវីដ-១៩ ដែលបញ្ជាក់ពីការចាក់វ៉ាក់សាំងកូវីដ-១៩ ពេញលេញ
- វិញ្ញាបនបត្របញ្ជាក់ថាគ្មានជំងឺកូវីដ-១៩ (តេស្ត PCR) ក្នុងរយៈពេល ៧២ម៉ោង មុនពេលមកដល់កម្ពុជា ទទួលស្គាល់ដោយអាជ្ញាធរសុខាភិបាលនៃប្រទេសសាមី ឬប្រទេសសំណាក់ចុងក្រោយមុនចាកចេញមកកាន់កម្ពុជា
- សេចក្តីប្រកាសសុខភាពរបស់អ្នកដំណើរ (Health Declaration of Travelers)
- សលាកប័ត្រចូល-ចេញ (Arrival / Departure Card)
- លិខិតរាយការណ៍គយ (Customs Declaration)
- ឯកសារពាក់ព័ន្ធផ្សេងទៀត ដែលតម្រូវដោយអាជ្ញាធរកម្ពុជា។

#### ១.២.២. សម្រាប់តែអ្នកដំណើរជាជនបរទេស

បន្ថែមពីលើឯកសារខាងលើ អ្នកដំណើរជាជនបរទេសត្រូវមានឯកសារ ដូចខាងក្រោម៖

- ទិដ្ឋាការ
- សលាកប័ត្រអន្តោប្រវេសន៍ (Immigration Card)
- ឯកសារពាក់ព័ន្ធផ្សេងទៀត ដែលតម្រូវដោយអាជ្ញាធរកម្ពុជា។

លើសពីនេះ អ្នកដំណើរជាជនបរទេសត្រូវបានលើកទឹកចិត្តឱ្យមាន៖

- បណ្ណសន្យារ៉ាប់រងសុខភាពសម្រាប់ព្យាបាលជំងឺកូវីដ-១៩ (COVID-19 Health Insurance Policy) ដែលនៅកម្ពុជាអាចទិញពីការធានារ៉ាប់រងរួមគ្នា (Insurance consortium) តំណាងដោយក្រុមហ៊ុនធានារ៉ាប់រងហ្វតតេ តាមរយៈគេហទំព័រ https://www.forteinsurance.com/covid-19-insurance/
- ឯកសារកក់សណ្ឋាគារសម្រាប់ការធ្វើចត្តាឡីស័ក រយៈពេល ១៤ថ្ងៃ ***(សម្រាប់អ្នកដំណើរជាជនបរទេស មិនបានចាក់វ៉ាក់សាំងកូវីដ-១៩ ពេញលេញ)***

ក្នុងដំណើរការនៃការបើកព្រំដែនឡើងវិញរបស់កម្ពុជា **ប្រព័ន្ធបណ្ណធ្វើដំណើរឌីជីថល (Digital Travel Pass)** អាចនឹងត្រូវបានរៀបចំនិងដាក់ឱ្យដំណើរការ សម្រាប់ធ្វើការផ្លាស់ប្តូរក្នុងក្របខណ្ឌយន្តការអន្តរជាតិ ឬទ្វេភាគី និងផ្តល់ភាពងាយស្រួល ដល់អ្នកដំណើរទាំងជនជាតិខ្មែរ និងបរទេស។

## ២. ពេលអ្នកដំណើរមកដល់អាកាសយានដ្ឋាន និងការត្រួតពិនិត្យរបស់មន្ត្រីពាក់ព័ន្ធ

### ២.១. ទីតាំងពិនិត្យសុខភាពបឋម (មន្ត្រីចត្តាឡីស័ក)

1. អ្នកដំណើរទាំងអស់ត្រូវឆ្លងកាត់ម៉ាស៊ីនស្កេនកម្តៅ
2. អ្នកដំណើរដែលមានកំដៅលើសពី ៣៧.៥ អង្សាសេ ឬមានរោគសញ្ញាសង្ស័យដូចជា ក្អកហៀរសំបោរ ឈឺបំពង់ក ហត់ ពិបាកដកដង្ហើម ជាដើម ត្រូវដាក់ឱ្យនៅដាច់ដោយឡែក រួចធ្វើតេស្តរហ័សរកអង់ទីហ្សែនកូវីដ-១៩ ជាបន្ទាន់ ដោយមានមន្ត្រីចត្តាឡីស័ក ឬមន្ត្រីសុខាភិបាល ដែលមានពាក់សម្លៀកបំពាក់ការពារខ្លួន (PPE) បានសមស្រប

2.1. អ្នកដំណើរដែលទទួលបានលទ្ធផលតេស្តរហ័សរកអង់ទីហ្សែនកូវីដ-១៩ វិជ្ជមាន ត្រូវយកសំណាកដើម្បីធ្វើតេស្ត PCR បញ្ជាក់ឡើងវិញ មុននឹងបញ្ជូនឱ្យទៅធ្វើចត្តាឡីស័កដាច់ដោយឡែកនៅទីកន្លែងដែលកំណត់ដោយក្រសួងសុខាភិបាល ឬអាជ្ញាធរមានសមត្ថកិច្ច (មន្ត្រីចត្តាឡីស័កត្រូវជួយសម្របសម្រួលឯកសារនិងឥវ៉ាន់របស់អ្នកដំណើរនេះតាមនីតិវិធី)

2.1.1. ប្រសិនបើលទ្ធផលតេស្ត PCR វិជ្ជមាន ត្រូវពិគ្រោះជាមួយគ្រូពេទ្យព្យាបាល ដើម្បីធ្វើការវាយតម្លៃស្ថានភាពសុខភាពជាក់ស្តែង និងសាកសួរពីទីកន្លែងស្នាក់នៅរបស់អ្នកជំងឺ៖

- បើអ្នកជំងឺពុំមានរោគសញ្ញា ឬមានរោគសញ្ញាកម្រិតស្រាល ហើយមានផ្ទះ ឬទីកន្លែងស្នាក់នៅសមស្រប មានអ្នកតាមដានជំងឺ និងពុំមានកត្តាប្រឈមនានា គាត់ត្រូវបានអនុញ្ញាតឱ្យធ្វើការព្យាបាលនៅផ្ទះ ដោយអនុវត្តតាមនីតិវិធីប្រតិបត្តិស្តង់ដា សម្រាប់គ្រប់គ្រង ថែទាំ និងព្យាបាលអ្នកជំងឺកូវីដ-១៩ នៅតាមផ្ទះ ហើយសាមីខ្លួនជាអ្នកជំងឺត្រូវទទួលខុសត្រូវលើការចំណាយពាក់ព័ន្ធនឹងការស្នាក់នៅព្យាបាលទាំងស្រុង

- បើអ្នកជំងឺពុំមានរោគសញ្ញា ឬមានរោគសញ្ញាកម្រិតស្រាល ប៉ុន្តែពុំមានផ្ទះ ឬទីកន្លែងស្នាក់នៅសមស្រប មានឬពុំមានអ្នកតាមដានជំងឺ និងពុំមានកត្តាប្រឈមនានា គាត់ត្រូវស្នាក់នៅព្យាបាលនៅក្នុងសណ្ឋាគារដែលទទួលបានការអនុញ្ញាតពីអាជ្ញាធរមានសមត្ថកិច្ច ដោយអនុវត្តតាមនីតិវិធីប្រតិបត្តិស្តង់ដា សម្រាប់គ្រប់គ្រង ថែទាំ និងព្យាបាលអ្នកជំងឺកូវីដ-១៩ នៅតាមផ្ទះ។ ចំពោះជនជាតិខ្មែរ ការព្យាបាលជំងឺកូវីដ-១៩ នៅមន្ទីរពេទ្យរដ្ឋ ជាបន្ទុករបស់រាជរដ្ឋាភិបាលកម្ពុជា។ ចំពោះជនបរទេស រាល់ការចំណាយពាក់ព័ន្ធនឹងការស្នាក់នៅនិងព្យាបាលជំងឺ ជាបន្ទុករបស់ក្រុមហ៊ុនធានារ៉ាប់រង (ប្រសិនបើបានទិញ) ឬសាមីខ្លួនជាអ្នកជំងឺ
- បើអ្នកជំងឺមានរោគសញ្ញាកម្រិតស្រាល មធ្យម ឬធ្ងន់ធ្ងរ និង/ឬមានកត្តាប្រឈមនានា គាត់ត្រូវស្នាក់នៅព្យាបាលនៅក្នុងមន្ទីរពេទ្យរដ្ឋឬឯកជនព្យាបាលជំងឺកូវីដ-១៩ ដែលទទួលបានការអនុញ្ញាតពីក្រសួងសុខាភិបាល ដោយអនុវត្តតាមមគ្គុទេសក៍សម្រាប់ការគ្រប់គ្រង និងការព្យាបាលជំងឺកូវីដ-១៩ នៅក្នុងព្រះរាជាណាចក្រកម្ពុជា។ ចំពោះជនជាតិខ្មែរ ការព្យាបាលជំងឺកូវីដ-១៩ នៅមន្ទីរពេទ្យរដ្ឋ ជាបន្ទុករបស់រាជរដ្ឋាភិបាលកម្ពុជា។ ចំពោះជនបរទេស រាល់ការចំណាយពាក់ព័ន្ធនឹងការស្នាក់នៅនិងព្យាបាលជំងឺ ជាបន្ទុករបស់ក្រុមហ៊ុនធានារ៉ាប់រង (ប្រសិនបើបានទិញ) ឬសាមីខ្លួនជាអ្នកជំងឺ

2.1.2. ប្រសិនបើលទ្ធផលតេស្ត PCR អវិជ្ជមាន ត្រូវបានអនុញ្ញាតឱ្យធ្វើដំណើរធម្មតា ឬធ្វើចត្តាឡីស័ក (សម្រាប់អ្នកដំណើរដែលពុំទាន់បានចាក់វ៉ាក់សាំងកូវីដ-១៩ ពេញលេញ)

2.2. អ្នកដំណើរដែលទទួលបានលទ្ធផលតេស្តរហ័សរកអង់ទីហ្សែនកូវីដ-១៩ អវិជ្ជមាន ត្រូវបានអនុញ្ញាតឱ្យបន្តការត្រួតពិនិត្យបែបបទ

3. អ្នកដំណើរដែលមានកំដៅតិចជាង ៣៧.៥ អង្សាសេ ឬគ្មានរោគសញ្ញាសង្ស័យ ឬអ្នកដំណើរដែលទទួលបានលទ្ធផលតេស្តរហ័សរកអង់ទីហ្សែនកូវីដ-១៩ អវិជ្ជមាន ត្រូវឆ្លងកាត់ការត្រួតពិនិត្យ និងសាកសួរដោយមន្ត្រីចត្តាឡីស័ក នូវឯកសារដែលពាក់ព័ន្ធ ដូចជា៖
   - លិខិតឆ្លងដែន
   - បណ្ណ ឬវិញ្ញាបនបត្រចាក់វ៉ាក់សាំងកូវីដ-១៩ ដែលបញ្ជាក់ពីការចាក់វ៉ាក់សាំងកូវីដ-១៩ ពេញលេញ
   - វិញ្ញាបនបត្របញ្ជាក់ថាគ្មានជំងឺកូវីដ-១៩ (តេស្ត PCR) ក្នុងរយៈពេល ៧២ម៉ោង មុនពេលមកដល់កម្ពុជា ទទួលស្គាល់ដោយអាជ្ញាធរសុខាភិបាលនៃប្រទេសសាមី ឬប្រទេសសំណាក់ចុងក្រោយមុនចាកចេញមកកាន់កម្ពុជា
   - បណ្ណសន្យារ៉ាប់រងសុខភាពសម្រាប់ព្យាបាលជំងឺកូវីដ-១៩ (បើមាន, សម្រាប់អ្នកដំណើរជាជនបរទេស)
   - ឯកសារកក់សណ្ឋាគារសម្រាប់ការធ្វើចត្តាឡីស័ក រយៈពេល ១៤ថ្ងៃ (បើមាន, សម្រាប់អ្នកដំណើរជាជនបរទេស មិនបានចាក់វ៉ាក់សាំងកូវីដ-១៩ ពេញលេញ)
   - សេចក្តីប្រកាសសុខភាពរបស់អ្នកដំណើរ (Health Declaration of Travelers)

4. មន្ត្រីចត្តាឡីស័ក និងមន្ត្រីពាក់ព័ន្ធទាំងអស់ត្រូវធ្វើការញែកអ្នកដំណើរដែលបាន ឬពុំទាន់បាន ចាក់វ៉ាក់សាំងកូវីដ-១៩ ពេញលេញ ទៅតាមជួរដែលបានកំណត់និងរៀបចំទុកជាស្រេចៈ
   - អ្នកដំណើរជាជនជាតិខ្មែរ ឬបរទេស ដែលបានចាក់វ៉ាក់សាំងកូវីដ-១៩ ពេញលេញ និង/ឬអ្នកដំណើរជាជនជាតិខ្មែរដែលពុំទាន់បានចាក់វ៉ាក់សាំងកូវីដ-១៩ ពេញលេញ ត្រូវបន្តដំណើរទៅកាន់បញ្ជរអន្តោប្រវេសន៍
   - អ្នកដំណើរជាជនបរទេសដែលពុំទាន់បានចាក់វ៉ាក់សាំងកូវីដ-១៩ ពេញលេញ និងគ្មានឯកសារកក់សណ្ឋាគារសម្រាប់ការធ្វើចត្តាឡីស័ក រយៈពេល ១៤ថ្ងៃ ត្រូវបន្តដំណើរទៅកាន់បញ្ជរធនាគារ
   - អ្នកដំណើរជាជនបរទេសដែលពុំទាន់បានទិញបណ្ណសន្យារ៉ាប់រងសុខភាពសម្រាប់ព្យាបាលជំងឺកូវីដ-១៩ ត្រូវបានលើកទឹកចិត្តឱ្យទិញបណ្ណសន្យារ៉ាប់រងសុខភាពសម្រាប់ព្យាបាលជំងឺកូវីដ-១៩ នៅបញ្ជរធនាគារ ឬត្រូវទទួលខុសត្រូវក្នុងការចំណាយព្យាបាលជំងឺកូវីដ-១៩ ដោយខ្លួនឯងទាំងស្រុង ប្រសិនបើមានការឆ្លងជំងឺកូវីដ-១៩ ឬមានជំងឺផ្សេងទៀត
5. មន្ត្រីចត្តាឡីស័កនិងមន្ត្រីសុខាភិបាលពាក់ព័ន្ធ ត្រូវមានៈ
   - សំលៀកបំពាក់និងសម្ភារៈបរិក្ខារការពារខ្លួន
   - ឧបករណ៍យកសំណាកនិងធ្វើតេស្តកូវីដ-១៩
   - ទម្រង់សេចក្តីប្រកាសសុខភាពរបស់អ្នកដំណើរ
   - ទម្រង់របាយការណ៍នានា
   - រថយន្តគិលានសង្គ្រោះប្រចាំការ ២៤ម៉ោង/៧ថ្ងៃ
   - ឯកសារ ឧបករណ៍ និងសម្ភារៈបរិក្ខារ ចាំបាច់ផ្សេងៗ បម្រើដល់ការងារ។

## ២.២. បញ្ជរធនាគារ

1. អ្នកដំណើរជាជនបរទេសដែលគ្មានបណ្ណ ឬវិញ្ញាបនបត្រចាក់វ៉ាក់សាំងកូវីដ-១៩ និងគ្មានឯកសារកក់សណ្ឋាគារសម្រាប់ការធ្វើចត្តាឡីស័ក រយៈពេល ១៤ថ្ងៃ ត្រូវទៅកាន់បញ្ជរធនាគារ ដើម្បីតម្កល់ប្រាក់២០០០ (ពីរពាន់) ដុល្លារអាម៉េរិក សម្រាប់ធានាចំណាយទាំងអស់ពាក់ព័ន្ធនឹងការធ្វើចត្តាឡីស័ក ក្នុងអំឡុងពេលធ្វើចត្តាឡីស័ករយៈពេល១៤ថ្ងៃ នៅទីកន្លែងដែលកំណត់ដោយក្រសួងសុខាភិបាល ឬអាជ្ញាធរមូលដ្ឋាន
2. អ្នកដំណើរជាជនបរទេសដែលពុំទាន់បានទិញបណ្ណសន្យារ៉ាប់រងសុខភាពសម្រាប់ព្យាបាលជំងឺកូវីដ-១៩ ត្រូវបានលើកទឹកចិត្តឱ្យទិញបណ្ណសន្យារ៉ាប់រងសុខភាពសម្រាប់ព្យាបាលជំងឺកូវីដ-១៩ នៅទីនោះ ឬត្រូវទទួលខុសត្រូវក្នុងការចំណាយព្យាបាលជំងឺកូវីដ-១៩ ដោយខ្លួនឯងទាំងស្រុង ប្រសិនបើមានការឆ្លងជំងឺកូវីដ-១៩ ឬមានជំងឺផ្សេងទៀត
3. អ្នកដំណើរដែលបានបញ្ចប់កិច្ចការនៅបញ្ជរធនាគាររួចរាល់ ត្រូវបន្តដំណើរទៅកាន់បញ្ជរអន្តោប្រវេសន៍។

## ២.៣. បញ្ជរអន្តោប្រវេសន៍

មន្ត្រីអន្តោប្រវេសន៍ត្រូវត្រួតពិនិត្យឯកសាររបស់អ្នកដំណើរទៅតាមសមត្ថកិច្ចរបស់ខ្លួន រួមមាន៖

- លិខិតឆ្លងដែន
- ទិដ្ឋាការ (សម្រាប់តែអ្នកដំណើរជាជនបរទេស)
- សលាកប័ត្រអន្តោប្រវេសន៍ (Immigration Card) (សម្រាប់តែអ្នកដំណើរជាជនបរទេស)
- សលាកប័ត្រចូល-ចេញ (Arrival / Departure Card)
- បណ្ណសន្យារ៉ាប់រងសុខភាពសម្រាប់ព្យាបាលជំងឺកូវីដ-១៩ (បើមាន, សម្រាប់អ្នកដំណើរជាជនបរទេស)
- ឯកសារកក់សណ្ឋាគារសម្រាប់ការធ្វើចត្តាឡីស័ក រយៈពេល ១៤ថ្ងៃ ឬលិខិតតម្កល់ប្រាក់២០០០ (ពីរពាន់) ដុល្លារអាម៉េរិក សម្រាប់ជានាចំណាយទាំងអស់ពាក់ព័ន្ធនឹងការធ្វើចត្តាឡីស័ក (សម្រាប់អ្នកដំណើរជាជនបរទេស មិនមានបណ្ណ ឬវិញ្ញាបនបត្រចាក់វ៉ាក់សាំងកូវីដ-១៩)។

## ២.៤. ទីតាំងយកឥវ៉ាន់ និងបញ្ជរត្រួតពិនិត្យគយ

បន្ទាប់មក អ្នកដំណើរទាំងអស់ត្រូវមកយកឥវ៉ាន់នៅទីតាំងយកឥវ៉ាន់ និងឆ្លងកាត់បញ្ជរត្រួតពិនិត្យគយ ដោយត្រូវប្រគល់លិខិតរាយការណ៍គយ ជូនដល់មន្ត្រីគយនិងរដ្ឋាករ។

## ២.៥. ទីតាំងយកសំណាកដើម្បីធ្វើតេស្តកូវីដ-១៩ (មន្ត្រីសុខាភិបាល)

អ្នកដំណើរទាំងអស់ត្រូវបានយកសំណាកដើម្បីធ្វើតេស្តរហ័សរកអង់ទីហ្សែនកូវីដ-១៩ ដោយមន្ត្រីសុខាភិបាល នៅទីតាំងដែលបានកំណត់ និងត្រូវរៀបចំទៅតាមលទ្ធផលដូចខាងក្រោម៖

1. ប្រសិនបើទទួលបានលទ្ធផលអវិជ្ជមាន អ្នកដំណើរទាំងអស់ត្រូវបានអនុញ្ញាតឱ្យបន្តទៅទីតាំងរៀបចំមធ្យោបាយធ្វើដំណើរចេញពីអាកាសយានដ្ឋាន
2. ប្រសិនបើទទួលបានលទ្ធផលវិជ្ជមាន ត្រូវយកសំណាកដើម្បីធ្វើតេស្ត PCR បញ្ជាក់ឡើងវិញ មុននឹងបញ្ជូនឱ្យទៅធ្វើចត្តាឡីស័កដាច់ដោយឡែកនៅទីកន្លែងដែលកំណត់ដោយក្រសួងសុខាភិបាល ឬអាជ្ញាធរមានសមត្ថកិច្ច ដើម្បីរង់ចាំលទ្ធផល។

ក្នុងករណីតម្រូវឱ្យអ្នកដំណើរបង់ប្រាក់លើការធ្វើតេស្តរហ័សរកអង់ទីហ្សែនកូវីដ-១៩ អ្នកដំណើរត្រូវបង់ប្រាក់តាមនីតិវិធីដែលកំណត់ដោយក្រសួងសុខាភិបាល។

## ២.៦. ទីតាំងរៀបចំមធ្យោបាយធ្វើដំណើរចេញពីអាកាសយានដ្ឋាន

មធ្យោបាយធ្វើដំណើរត្រូវរៀបចំដាច់ដោយឡែកពីគ្នា រវាងអ្នកដំណើរដែលបាន ឬពុំទាន់បានចាក់វ៉ាក់សាំងកូវីដ-១៩ ពេញលេញ។ អ្នកដំណើរដែលពុំទាន់បានចាក់វ៉ាក់សាំងកូវីដ-១៩ ពេញលេញ ត្រូវធ្វើចត្តាឡីស័ករយៈពេល ១៤ថ្ងៃ នៅសណ្ឋាគារដែលបានកក់ ឬទីតាំងដែលកំណត់ដោយក្រសួងសុខាភិបាល ឬអាជ្ញាធរមានសមត្ថកិច្ច។

### ២.៧. ទីតាំងធ្វើចត្តាឡីស័កដាច់ដោយឡែក

អ្នកដំណើរដែលទទួលបានលទ្ធផលតេស្តរហ័សរកអង់ទីហ្សែនកូវីដ-១៩ វិជ្ជមាន ត្រូវយកសំណាកដើម្បីធ្វើតេស្ត PCR បញ្ជាក់ឡើងវិញ មុននឹងបញ្ជូនឱ្យទៅធ្វើចត្តាឡីស័កដាច់ដោយឡែកនៅទីកន្លែងដែលកំណត់ដោយក្រសួងសុខាភិបាល ឬអាជ្ញាធរមានសមត្ថកិច្ច ដើម្បីរង់ចាំលទ្ធផលតេស្ត។ អ្នកដំណើរជាជនបរទេសត្រូវរ៉ាប់រងចំណាយពាក់ព័ន្ធផ្សេងៗដោយខ្លួនឯង ក្នុងអំឡុងពេលធ្វើចត្តាឡីស័កដាច់ដោយឡែកនេះ។

## ៣. លក្ខខណ្ឌវ៉ាក់សាំងកូវីដ-១៩ សម្រាប់អ្នកដំណើរអាយុក្រោម ១៨ឆ្នាំ

### ៣.១. អ្នកដំណើរអាយុក្រោម ១៨ឆ្នាំ រួមដំណើរជាមួយអាណាព្យាបាល

អ្នកដំណើរ អាយុក្រោម ១៨ឆ្នាំ ដែលពុំទាន់បានចាក់វ៉ាក់សាំងកូវីដ-១៩ ពេញលេញ ហើយរួមដំណើរជាមួយអាណាព្យាបាល ត្រូវអនុវត្តគោលការណ៍មាន ឬគ្មានចត្តាឡីស័ក អនុលោមទៅតាមលក្ខខណ្ឌរបស់អាណាព្យាបាល ដែលជននោះរួមដំណើរជាមួយ។

### ៣.២. អ្នកដំណើរអាយុក្រោម ១៨ឆ្នាំ ធ្វើដំណើរទោល ឬជាក្រុម ដោយពុំមានអាណាព្យាបាលមកជាមួយ

អ្នកដំណើរអាយុក្រោម ១៨ឆ្នាំ ដែលពុំទាន់បានចាក់វ៉ាក់សាំងកូវីដ-១៩ ពេញលេញ ធ្វើដំណើរទោល ឬជាក្រុម ដោយពុំមានអាណាព្យាបាលផ្ទាល់មកជាមួយ ត្រូវធ្វើចត្តាឡីស័ក រយៈពេល ១៤ថ្ងៃ នៅសណ្ឋាគារដែលបានកក់ ឬទីតាំងដែលកំណត់ដោយក្រសួងសុខាភិបាល ឬអាជ្ញាធរមានសមត្ថកិច្ច។

## ៤. នីតិវិធីបន្ថែម ឬដាច់ដោយឡែក

ក្នុងករណីចាំបាច់ ដោយផ្អែកលើស្ថានភាពវិវត្តន៍ជាក់ស្តែងនៃជំងឺកូវីដ-១៩ ពិសេសវីរុសបំប្លែងថ្មីៗ អ្នកដំណើរដែលមកពីប្រទេស ឬតំបន់ហានិភ័យមួយចំនួនដែលបាននិងកំពុងផ្ទុះវីរុសបំប្លែងថ្មី ត្រូវអនុវត្តតាមនីតិវិធីបន្ថែម ឬដាច់ដោយឡែកមានជាអាទិ៍ លក្ខខណ្ឌធ្វើដំណើរ ការអនុវត្តវិធានការសុខាភិបាល និងការធ្វើចត្តាឡីស័ក ដែលកំណត់ដោយសេចក្តីជូនដំណឹងឬសេចក្តីប្រកាសព័ត៌មានរបស់ក្រសួងសុខាភិបាល។

# គំនូសបំព្រួញរំហូរការងារគ្រប់គ្រងអ្នកដំណើរមកដល់អាកាសយានដ្ឋានអន្តរជាតិនៅកម្ពុជា

**អ្នកដំណើរមកដល់អាកាសយានដ្ឋានអន្តរជាតិនៅកម្ពុជា**

១

**ទីតាំងពិនិត្យសុខភាពបឋម ( មន្ត្រីចត្តាឡីស័ក )**

**ម៉ាស៊ីនស្កេនកំដៅ**

- កំដៅលើសពី ៣៧.៥ អង្សាសេ ឬមានរោគសញ្ញាសង្ស័យ
  - តេស្តរហ័ស Ag (+)
  - តេស្តរហ័ស Ag (-)
- កំដៅតិចជាង ៣៧.៥ អង្សាសេ ឬគ្មានរោគសញ្ញាសង្ស័យ

ពិនិត្យឯកសារពាក់ព័ន្ធនានា

បណ្ណ ឬវិញ្ញាបនបត្រចាក់វ៉ាក់សាំងកូវីដ-១៩

- មាន
- គ្មាន
  - ខ្មែរ
  - បរទេស → **បញ្ជរធនាគារ**

២

- ជនបរទេសដែលគ្មានបណ្ណ ឬវិញ្ញាបនបត្រចាក់វ៉ាក់សាំងកូវីដ-១៩ និងគ្មានឯកសារកក់សណ្ឋាគារសម្រាប់ការធ្វើចត្តាឡីស័ក រយៈពេល ១៤ថ្ងៃ ត្រូវទៅកាន់បញ្ជរធនាគារ ដើម្បីតម្កល់ប្រាក់២,០០០ដុល្លារអាមេរិក សម្រាប់ជានាចំណាយទាំងអស់ពាក់ព័ន្ធនឹងការធ្វើចត្តាឡីស័ក ក្នុងអំឡុងពេលធ្វើចត្តាឡីស័ករយៈពេល១៤ថ្ងៃ នៅទីកន្លែងដែលកំណត់ដោយក្រសួងសុខាភិបាល ឬអាជ្ញាធរមូលដ្ឋាន
- ជនបរទេសដែលពុំទាន់បានទិញបណ្ណសន្យារ៉ាប់រងសុខភាពសម្រាប់ព្យាបាលជំងឺកូវីដ-១៩ ត្រូវបានលើកទឹកចិត្តឱ្យទិញបណ្ណសន្យារ៉ាប់រងសុខភាពសម្រាប់ព្យាបាលជំងឺកូវីដ-១៩ នៅទីនេះ ឬត្រូវទទួលខុសត្រូវក្នុងការចំណាយព្យាបាលជំងឺកូវីដ-១៩ ដោយខ្លួនឯងទាំងស្រុង ប្រសិនបើមានការឆ្លងជំងឺកូវីដ-១៩ ឬមានជំងឺផ្សេងទៀត។

៣

**បញ្ជរអន្តោប្រវេសន៍**

៤

**ទីតាំងយកឥវ៉ាន់ និងបញ្ជរគ្រួតពិនិត្យគយ**

**បញ្ជរបង់ប្រាក់ធ្វើតេស្តកូវីដ-១៩**
(នៅពេលតម្រូវឱ្យបង់ប្រាក់)

៥

**ទីតាំងយកសំណាកដើម្បីធ្វើតេស្តកូវីដ-១៩ ( មន្ត្រីសុខាភិបាល )**

- តេស្តរហ័ស Ag (+)
- តេស្តរហ័ស Ag (-)

៦

**ទីតាំងធ្វើចត្តាឡីស័កដាច់ដោយឡែក**

- តេស្ត PCR (+) → **រថយន្តគិលានសង្គ្រោះ** → ព្យាបាលតាមកម្រិតជំងឺ
- តេស្ត PCR (-) → អនុញ្ញាតឱ្យធ្វើដំណើរធម្មតា ឬធ្វើចត្តាឡីស័ក

៧

**ទីតាំងរៀបចំមធ្យោបាយធ្វើដំណើរចេញពីអាកាសយានដ្ឋាន**

អនុញ្ញាតឱ្យធ្វើដំណើរធម្មតា ឬធ្វើចត្តាឡីស័ក

**ប្រព័ន្ធបណ្ណធ្វើដំណើរឌីជីថល**
(នៅពេលដែលដាក់ឱ្យដំណើរការ)

**ឯកសារដែលអ្នកដំណើរមកដល់ត្រូវត្រៀម ដើម្បីបង្ហាញដល់អាជ្ញាធរពាក់ព័ន្ធ មានដូចខាងក្រោម៖**

**សម្រាប់អ្នកដំណើរជាជនជាតិខ្មែរ និងជនបរទេស៖**

- លិខិតឆ្លងដែន
- បណ្ណ ឬវិញ្ញាបនបត្រចាក់វ៉ាក់សាំងកូវីដ-១៩ ដែលបញ្ជាក់ពីការចាក់វ៉ាក់សាំងកូវីដ-១៩ ពេញលេញ
- វិញ្ញាបនបត្របញ្ជាក់ថាគ្មានជំងឺកូវីដ-១៩ (តេស្ត PCR) ក្នុងរយៈពេល ៧២ម៉ោង មុនពេលមកដល់កម្ពុជា ទទួលស្គាល់ដោយអាជ្ញាធរសុខាភិបាលនៃប្រទេសសាមី ឬប្រទេសសំណាក់ចុងក្រោយ
- សេចក្តីប្រកាសសុខភាពរបស់អ្នកដំណើរ
- សលាកប័ត្រចូល-ចេញ
- លិខិតរាយការណ៍គយ

**ឯកសារបន្ថែម សម្រាប់អ្នកដំណើរជាជនបរទេស៖**

- ទិដ្ឋាការ
- សលាកប័ត្រអន្តោប្រវេសន៍
- ឯកសារផ្សេងទៀត ដែលតម្រូវដោយអាជ្ញាធរកម្ពុជា

**អ្នកដំណើរជាជនបរទេស ត្រូវបានលើកទឹកចិត្តឱ្យមាន៖**

- បណ្ណសន្យារ៉ាប់រងសុខភាពសម្រាប់ព្យាបាលជំងឺកូវីដ-១៩ (COVID-19 Health Insurance Policy) ដែលនៅកម្ពុជាអាចទិញពីការធានារ៉ាប់រងរួមគ្នា (Insurance consortium) តំណាងដោយក្រុមហ៊ុនធានារ៉ាប់រងហ្វតេ តាមរយៈគេហទំព័រ https://www.forteinsurance.com/covid-19-insurance/
- ឯកសារកក់សណ្ឋាគារសម្រាប់ការធ្វើចត្តាឡីស័ករយៈពេល ១៤ថ្ងៃ (សម្រាប់អ្នកដំណើរជាជនបរទេស មិនបានចាក់វ៉ាក់សាំងកូវីដ-១៩ ពេញលេញ)

អនុញ្ញាតឱ្យព្យាបាលនៅផ្ទះ ឬមន្ទីរពេទ្យព្យាបាលជំងឺកូវីដ-១៩ (រដ្ឋ ឬឯកជន) ផ្អែកលើការវាយតម្លៃកម្រិតជំងឺ និងលក្ខខណ្ឌពាក់ព័ន្ធនានារបស់អ្នកជំងឺ។ ចំពោះជនបរទេស រាល់ការចំណាយពាក់ព័ន្ធនឹងការស្នាក់នៅនិងព្យាបាលជំងឺ ជាបន្ទុករបស់ក្រុមហ៊ុនធានារ៉ាប់រង (ប្រសិនបើបានទិញ) ឬសាមីខ្លួនជាអ្នកជំងឺ។

(លក្ខខណ្ឌផ្សេងៗត្រូវបានអនុវត្ត)

- អ្នកដំណើរដែលទទួលបានលទ្ធផលតេស្តរហ័សរកអង់ទីហ្សែនកូវីដ-១៩ អវិជ្ជមាន ត្រូវបានអនុញ្ញាតឱ្យចេញពីអាកាសយានដ្ឋាន ដោយត្រូវអនុវត្តតាមលក្ខខណ្ឌមាន ឬគ្មានបណ្ណ ឬវិញ្ញាបនបត្រចាក់វ៉ាក់សាំងកូវីដ-១៩ ឬនីតិវិធីដាច់ដោយឡែក
- អ្នកដំណើរដែលទទួលបានលទ្ធផលតេស្ត PCR អវិជ្ជមាន ត្រូវបានអនុញ្ញាតឱ្យចេញពីទីតាំងធ្វើចត្តាឡីស័កដាច់ដោយឡែក ដោយត្រូវអនុវត្តតាមលក្ខខណ្ឌមាន ឬគ្មានបណ្ណ ឬវិញ្ញាបនបត្រចាក់វ៉ាក់សាំងកូវីដ-១៩ ឬនីតិវិធីដាច់ដោយឡែក
- អ្នកដំណើរដែលពុំទាន់បានចាក់វ៉ាក់សាំងកូវីដ-១៩ ពេញលេញ ត្រូវធ្វើចត្តាឡីស័ក រយៈពេល ១៤ថ្ងៃ នៅសណ្ឋាគារដែលបានកក់ ឬទីតាំងដែលកំណត់ដោយក្រសួងសុខាភិបាល ឬអាជ្ញាធរមានសមត្ថកិច្ច។